**សប្តាហ៍ពិភពលោកបំបៅដោះកូនដោយទឹកដោះម្តាយ ឆ្នាំ២០២៣**

ការប្រកួតប្រជែង និងពានរង្វាន់សម្រាប់អ្នកសារព័ត៌មាន

ក្រោមប្រធានបទ៖ **"បង្កើតបរិយាកាសងាយស្រួលនៅកន្លែងការងារដើម្បីលើកកម្ពស់ការចិញ្ចឹមកូនដោយទឹកដោះម្តាយ"**

# លក្ខន្តិកនៃការប្រកួតប្រជែង

## ១.១. សារតា

ប្រព័ន្ធផ្សព្វផ្សាយដើរតួនាទីយ៉ាងសំខាន់ក្នុងជីវិតប្រចាំថ្ងៃ ដែលជះឥទ្ធិពលដល់ការយកចិត្តទុកដាក់របស់ប្រជាពលរដ្ឋ និងផ្តល់នូវការពិត និងមតិជាច្រើន ដែលបង្កើតទស្សនៈផ្សេងៗ លើប្រធានបទនានាប្រចាំថ្ងៃ។ ពួកយើងរំពឹងថា ការប្រកួតប្រជែងនេះ នឹងជំរុញឱ្យអ្នកសារព័ត៌មានសរសេរអត្ថបទ ឬបទយកការណ៍កាន់តែច្រើនពីសារៈសំខាន់នៃការបំបៅកូនដោយទឹកដោះម្តាយ បញ្ហាប្រឈម ដែលឪពុកម្តាយកំពុងប្រកបការងារជួបប្រទះ និងដំណោះស្រាយដើម្បីជម្នះបញ្ហាប្រឈម និងឧបសគ្គចំពោះការបំបៅកូនដោយទឹកដោះម្តាយ។ សកម្មភាពនេះ ក៏អាចមានឥទ្ធិពលលើគោលនយោបាយ និងអ្នកធ្វើសេចក្តីសម្រេចចិត្ត ដើម្បីបង្កបរិយាកាសកាន់តែអំណោយផលបន្ថែមទៀត សម្រាប់ការបំបៅកូនដោយទឹកដោះម្តាយ នៅកម្ពុជា។

ការប្រកួតប្រជែងនេះ បើកចំហសម្រាប់អ្នកសារព័ត៌មានក្នុងការបញ្ជូនស្នាដៃរបស់ខ្លួនជាភាសាខ្មែរ ក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ក្នុងឱកាសការប្រារព្ធសប្តាហ៍ពិភពលោកបំបៅកូនដោយទឹកដោះម្តាយ ក្រោមប្រធានបទ៖"បង្កើតបរិយាកាសងាយស្រួលនៅកន្លែងការងារដើម្បីកម្ពស់ការចិញ្ចឹមកូនដោយទឹកដោះម្តាយ"។ អត្ថបទ ឬបទយកការណ៍របស់អ្នកសារព័ត៌មាន នឹងត្រូវដាក់ពិន្ទុដោយតំណាងអង្គការធ្វើការផ្នែកសុខភាព និងអាហាររូបត្ថម្ភ រួមនឹងអ្នកជំនាញផ្នែកប្រព័ន្ធផ្សព្វផ្សាយ។

## ១.២. លក្ខខណ្ឌនៃការចូលរួម

- ការប្រកួតប្រជែងនេះ បើកចំហសម្រាប់អ្នកសារព័ត៌មានអាជីព។
- ដើម្បីចូលរួមក្នុងការប្រកួតនេះ អ្នកចូលរួមទាំងអស់ត្រូវបំពេញ ទម្រង់បែបបទអនឡាញ ។
- អត្ថបទសារព័ត៌មាន ឬបទយកការណ៍ ត្រូវតែជាភាសាខ្មែរ និងមិនធ្លាប់បានដាក់សម្រាប់ការប្រកួតប្រជែងណាមួយពីមុនមក។

- អង្គការទស្សនៈពិភពលោកអន្តរជាតិ និងគណៈកម្មការរក្សាសិទ្ធិកែប្រែកាលបរិច្ឆេទឈប់ទទួលអត្ថបទ ឬបទយកការណ៍ ដោយផ្អែកលើចំនួន និងគុណភាពដែលបានផ្ញើមកមកកាន់ក្រុមការងារសម្រាប់ការប្រកួតនេះ។
- បេក្ខជនត្រូវបញ្ជូនស្នាដៃរបស់ខ្លួន តាមរយៈតេលេក្រាម: +855 76 272 372 ; ឬអ៊ីមែលះ media_cambodia@wvi.org។
- អង្គការទស្សនៈពិភពលោកអន្តរជាតិប្រចាំនៅកម្ពុជា និងគណៈកម្មាការរក្សាសិទ្ធិក្នុងការដកចេញនូវអត្ថបទណាមួយដែលមានខ្លឹមសារប្រមាថ ឬមិនសមរម្យ។

## ១.៣. រង្វាន់

- អ្នកទទួលបានជ័យលាភី នឹងទទួលបានពានរង្វាន់ វិញ្ញាបនបត្រ និងរង្វាន់។
- រង្វាន់នឹងត្រូវបានផ្តល់ជូនដល់អ្នកសារព័ត៌មានដែលសរសេរអត្ថបទ ឬបទយកការណ៍ ឆ្លុះបញ្ចាំងពីសារៈសំខាន់នៃការបំបៅកូនដោយទឹកដោះម្តាយ ហើយជំរុញឱ្យមានការគាំទ្រដល់ការបង្កបរិយាកាសកាន់តែអំណោយផល សម្រាប់ឪពុកម្តាយដែលប្រកបការងារ។

## ១.៤. គណៈកម្មាការដាក់ពិន្ទុ

គណៈកម្មការដាក់ពិន្ទុ ជាបុគ្គលិកផ្នែកទំនាក់ទំនង និងបុគ្គលិកបច្ចេកទេសមកពីអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ រួមមានៈ Alive & Thrive (A&T), អង្គការហេឡេនឃេល័រ, អង្គការផ្លែនអន្តរជាតិ (PIC) អង្គការទស្សនៈពិភពលោក (WVI) អង្គការយូនីសេហ្វ (Unicef) អង្គការសុខភាពពិភពលោក (WHO) និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

## ១.៥. លក្ខខណ្ឌវិនិច្ឆ័យ

គណៈកម្មការនឹងជ្រើសរើសប្រាំ (០៥) ស្នាដៃដែលសរសេរល្អបំផុត ដោយផ្អែកលើះ ខ្លឹមសារ(៣០%) រចនាសម្ព័ន្ធ(១៥%) ឥទ្ធិពលឬផលជះនៃសាច់រឿង (៤០%) និងគុណភាពនៃរូបភាព(១៥%) ។

**១. ខ្លឹមសារ (៣០%)**

- មុំនៃរឿងះ តើសាច់រឿងមានជាប់ពាក់ព័ន្ធនឹងប្រធានបទកម្រិតណា?
- តើមុំនៃរឿងគួរឱ្យចាប់អារម្មណ៍ ឬថ្មីដែលមិនទាន់មានការរាយការណ៍ពីមុនមកដែរទេ ?
- ភាពត្រឹមត្រូវះ តើសាច់រឿង មានបញ្ចូលនូវរបាយការណ៍ តួលេខ សម្រង់សម្តីបានត្រឹមត្រូវដែរឬទេ?
- បង្ហាញពីការរាយការណ៍ប្រកបដោយតុល្យភាព ដោយដាក់បញ្ចូលទស្សនៈផ្សេងៗគ្នាពីភាគីពាក់ព័ន្ធ ។
- ភាពសាមញ្ញនៃសាច់រឿងះ អ្នកសារព័ត៌មាន ប្រើប្រាស់ភាសាសាមញ្ញ ដែលធ្វើឱ្យអ្នកអានងាយយល់។

**២. រចនាសម្ព័ន្ធ (១៥%)៖** លំហូរនៃព័ត៌មាន

**៣.ឥទ្ធិពលឬផលជះដែលមានសក្តានុពលផលប៉ះពាល់(៤០%)៖**

- តើសារត្រូវបានដាក់បញ្ចូលទៅក្នុងអត្ថបទរឿងបានល្អប៉ុណ្ណា?
- បង្ហាញដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតដើម្បីលើកកម្ពស់ និង/ឬបង្កើតបរិយាកាសកាន់តែអំណោយផល សម្រាប់ឪពុកម្តាយប្រកបការងារឱ្យបំបៅកូនដោយទឹកដោះម្តាយ។
- អំពាវនាវឱ្យមានអន្តរាគមន៍
- អនុសាសន៍/សំណូមពរ

**៤. គុណភាពរូបភាព (១៥%)**

- រូបភាពគុណភាព Full HD
- រូបភាពឆ្លុះបញ្ចាំងពីប្រធានបទ ។
- រូបភាព ត្រូវតែមានលក្ខណៈដើម និងមិនមានផ្លាកសញ្ញា ឬសញ្ញាសម្គាល់ ( Water mark )។
- រូបថតបង្ហាញពីការបំផុសគំនិត និងលើកតម្កើងសេចក្តីថ្លៃថ្នូររបស់តួអង្គ។ គោលនយោបាយការពាររបស់អង្គការទស្សនៈពិភពលោក ជួយអ្នកសារព័ត៌មាន ធានានូវសេចក្តីថ្លៃថ្នូររបស់តួអង្គ ដោយមិនធ្វើឱ្យពួកគេប្រឈមនឹងគ្រោះថ្នាក់ណាមួយឡើយ ។

  1_Safeguarding_for_Field_Communic
- អនុញ្ញាតឱ្យមានការកែសម្រួលរូបភាពបន្តិចបន្តួច (ពន្លឺ និងពណ៌) តែរក្សាខ្លឹមសារដើម។

## ១.៦. កម្មសិទ្ធិបញ្ញា

អ្នកសារព័ត៌មាន ទទួលការយល់ព្រមពីតួអង្គ ដែលបង្ហាញក្នុងរូបភាពណាមួយ ជាផ្នែកនៃការប្រកួតនេះ។ អ្នកចូលរួម ត្រូវប្រកាសថា រូបភាពទាំងឡាយណាដែលបានប្រើប្រាស់នៅក្នុងការប្រកួតដែលខ្លួននិង/ឬសហការីរបស់ខ្លួនបានថត បានទទួលការអនុញ្ញាតឱ្យប្រើសម្រាប់ការប្រកួតប្រជែង ហើយថារូបភាពទាំងនេះនឹងត្រូវបានប្រើប្រាស់ដោយស្ថាប័នដែលបានរៀបចំការប្រកួតប្រជែងនេះ ។

## ១.៧. កាលបរិច្ឆេទសម្រាប់ការប្រកួត

- ប្រកាសការប្រកួត៖ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣
- សិក្ខាសាលាតម្រង់ទិសដល់អ្នកសារព័ត៌មានដែលចាប់អារម្មណ៍(តាមអនឡាញ)៖ ថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣
- កាលបរិច្ឆេទឈប់ទទួលអត្ថបទ ឬបទយកការណ៍ ៖ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៣
- ការវាយតម្លៃលើស្នាដៃដែលបានដាក់ប្រកួតប្រជែង៖ ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣
- ពិធីប្រគល់រង្វាន់៖ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣

## WORLD BREASTFEEDING WEEK CELEBRATION - 2023

**Competition and Awards for Journalists on the theme**
**"Enabling Breastfeeding: Making a Difference for Working Parents"**

### Terms and Conditions

### 1.1 Background

Media plays a major role in public life, influencing citizens focus of attention and providing many facts and opinions that shape perspectives on topics of the day. It is envisaged that this competition will ignite passion among journalists to write more on the importance of breastfeeding, challenges faced by working parents (mother and father) and feasible solutions taken up by working parents to overcome the challenges and barriers to breastfeed. This could potentially influence policy and decision makers to create a more friendly environment for breastfeeding in the country.

This is an open announcement made to journalists to submit their written work on the theme "Enabling breastfeeding: Making a difference for working parents" in Khmer, written exclusively for this competition. The submitted work will be judged by a panel comprising of experts from relevant INGOs and faculty from media school.

### 1.2 Entry Criteria

- This competition is open for professional journalists.
- To participate in this competition, all participants must fill in the Online Entry Form.
- The submissions in Khmer are only accepted.
- World Vision International in Cambodia, along with the panel, reserves the right to extend the duration of the closing date for the competition based on the number and quality of the final content submitted for this competition.
- The applicants shall submit their work either through Telegram: +855 76 272 372, or email: media_cambodia@wvi.org.
- World Vision International in Cambodia, along with the panel, reserves the right to disqualify any entry that contains hurtful, misleading, libelous or vulgar content.

### 1.3 Award

- Awards will be given as trophies, certificates, prizes.
- Awards will be presented to journalists who submit written articles that demonstrate exemplary reporting on the importance of breastfeeding and that can

be used to support the creation of an enabling (positive) environment for working parents.

### 1.4. Judges – Panel Composition

The panel will consist of Communication staff and technical staff from International Non-Governmental Organisations, UN Organisations and Media Academy (including Alive and Thrive (A&T), Hellen Keller International, Plan International, World Vision International, UNICEF, WHO and Department of Media and Communication and the Royal University of Phnom Penh).

### 1.5 Judgement Criteria

The panel will select Five (05) of the best written pieces of work assessed according to the following criteria: content (30%), structure (15%), potential impact (40%) and quality of pictures (15%) and award them the prizes.

1. Content (30%)
    - Angle of the story: Does the story contain a central or dominating theme?
    - Is the angle of the story relevant to the theme and is it interesting, or new, worth capturing?
    - Accuracy: Gathers material using firsthand sources and/ or second-hand sources that are properly referenced;
    - Portrays balanced reporting giving due consideration to the different points of view of the stakeholders concerned;
    - Simplicity of the story: The story must be well understood by general audiences.
2. Structure (15%): Flow of the information
3. Potential impact (40%): How well is the message integrated into the story?
    - Present creative solutions to promote and/or create a friendly environment for working parents to breastfeed.
    - Call to Action
    - Recommendations/ suggestions
4. Quality of Pictures (15%)
    - Full HD quality photo
    - The visuals should be clear and address the theme.
    - The photos must be original and do not contain any water marks.
    - The photos convey inspiration and uphold the dignity of the subject. World Vision's Safeguarding Policy helps journalists, reporters, and communicators to ensure subject's dignity is protected without exposing them to any harm.

      1_Safeguarding_fo r_Field_Communic
    - Basic editing and retouching are allowed.

### 1.6 Intellectual Property

The participant declares that he/she has directly received valid consent from the subject (s) appearing in any image as part of this contest. The participants declare that any images involved in the submission were taken by him/her or that he/she received permission to use them in his/her submission, and that the images may be used by INGOs and Civil Society who have called for this competition.

### 1.7 Timelines for the competition:

- Announcing the competition: 28th July, 2023
- Orientation to the interested journalists (online): 2 August, 2023
- Submission of the written work: 27 August, 2023
- Review of the written works: 29 August, 2023
- Award ceremony: 14th September, 2023